- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពកាយយកដីភ្នំ និងការកាប់ទន្ទ្រានព្រៃក្នុងឧទ្យានជាតិកែប ភ្នំ និងកសាងជញ្ជាំងទប់ភ្នំ ដើម្បីចៀសវាងកុំឱ្យរអិលបាក់ដីភ្នំ
- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពបូមយកដីនៅក្នុងបាតសមុទ្រដែលមិនសមស្របតាមបទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបាននិរន្តរភាពតំបន់ទេសចរធម្មជាតិស្ងប់ស្ងាត់ និងស្នាក់នៅរយៈពេលយូរ
- ពង្រឹងយន្តការ និងមធ្យោបាយសម្រាប់បង្ការទប់ស្កាត់ និងប្រឆាំងភ្លើងឆេះព្រៃនៅក្នុងឧទ្យានជាតិ ភ្នំ និងនៅលើកោះ។

## ៥.៤.២-ការអនុវត្តរយៈពេលមធ្យម

- កសាងសមត្ថភាពធ្វើផែនការក្រុង
- ផែនទីកំណត់តំបន់អភិវឌ្ឍន៍ជាអាទិភាព
- ប្លង់អភិវឌ្ឍន៍ទិសខាងជើង
- រៀបចំគម្រោងកែលម្អឆ្នេរកែប ចាប់ពីចំណុចសំណង់មិនរៀបរយមកដល់កំពង់ផែ និងចេញពីកំពង់ផែមកដល់រូបសំណាកស្រីស ដោយមានផ្លូវប្រឡមាត់សមុទ្រ សួនកម្សាន្ត សួនកុមារ សួនលម្ហែកាយ ទីលានសម្រាប់ប្រជាពលរដ្ឋមកពីបណ្តាខេត្តឆ្ងាយៗ ទីលានសម្រាប់បុណ្យសមុទ្រវិញជុំ ចំណតយានយន្ត បន្ទប់ទឹកអនាម័យសាធារណៈ
- ពង្រីកឆ្នេរកម្សាន្តនៅចំណុចពយព្រះរាជដំណាក់ឱ្យមានចំណតរថយន្ត សួនច្បារលម្ហែកម្សាន្ត សួនកុមារ ផ្សាររាត្រី ទីលានសម្រាប់ប្រជាពលរដ្ឋមកពីបណ្តាខេត្តឆ្ងាយៗកម្សាន្ត និងសេវាបម្រើវិស័យទេសចរណ៍ផ្សេងៗទៀត
- កែលម្អផ្លូវព័ទ្ធព័ទ្ធជុំវិញទំនប់ប៉ោហេង ដើម្បីបង្កើតបន្ថែមទៀតនូវតំបន់ទេសចរណ៍
- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងសាធារណៈខេត្តកែបលើវិស័យទេសចរណ៍
- អភិវឌ្ឍ និងលើកកម្ពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិ
- កែលម្អ និងពង្រីកផ្លូវជាតិលេខ៣៣អា វិថី អនុវិថី ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន ចិញ្ចើមផ្លូវ ភ្លើងបំភ្លឺ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម កំណត់ប្រភេទដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ សួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង នៅក្នុងក្រុងកែបស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយផាសុកភាពល្អ សម្រាប់មនុស្សទាំងអស់គ្នា
- កសាងផ្លូវប្រឡមាត់សមុទ្រ តភ្ជាប់ជាមួយនឹងផ្លូវប្រឡមាត់សមុទ្រខេត្តកំពត
- កែលម្អ និងថែទាំបណ្តាញផ្លូវដែលមានស្រាប់ក្នុងក្រុងអមដោយដើមរុក្ខជាតិផ្កា និងដើមឈើលម្អអមសងខាងផ្លូវ និងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បរិក្ខាផ្លូវថ្នល់ ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រង និងបង្គោលភ្លើងភ្លឺចម្រុះពណ៌

- បណ្តុះបណ្តាលដល់ប្រជាកសិករអំពីផលប្រយោជន៍ និងវិធីសាស្ត្រក្នុងការប្រើប្រាស់ជីសរីរាង្គ
- អនុវត្តដំណើរការសហគមន៍មួយ ផលិតផលមួយ
- ផ្សព្វផ្សាយផលិតផល និងពង្រីកផ្ទៃដីដាំដំណាំម្រេច និងធុរេន
- ពង្រីកការកែច្នៃធនធានសមុទ្រ ដើម្បីលក់ជូនភ្ញៀវទេសចរ
- អប់រំ និងផ្សព្វផ្សាយដល់ប្រជាជនអំពីគោលការណ៍គ្រប់គ្រងសំណល់រឹង តាមរយៈការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ
- កសាងអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅឆ្នេរកែប ឆ្នេរថ្មី តំបន់ក្រោយផ្សារកែប ផ្សារដំណាក់ចង្អើរ និងទីប្រជុំជនផ្សារសេះស ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលលូសាធារណៈ
- ពង្រីកតំបន់ទទួលបានការផ្គត់ផ្គង់ប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ឱ្យបានគ្របដណ្តប់ទូទាំងក្រុង
- ណែនាំម្ចាស់សំណង់លំនៅឋាន សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈឱ្យរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។

### ៥.៤.៣- ការអនុវត្តរយៈពេលវែង

- សាងសង់ស្ពានរំលង ស្ថិតនៅចំណុចរូបសំណាកស្រីស
- រៀបចំឱ្យមានរង្វង់មូលផ្លូវកែង ត្រង់ចំណុចរូបសំណាកស្តេចកន និងរង្វង់មូលជាច្រើនទៀតនៃផ្លូវប្របមាត់សមុទ្រ
- កសាងកំពង់ផែទេសចរណ៍កម្រិតអន្តរជាតិត្រង់ចំណុចកំពង់ផែចាស់ និងជីកឃ្លងដើម្បីឱ្យទឹកសមុទ្រជ្រៅ ដែលបង្កឱ្យនាវាទេសចរណ៍ចូលចតបាន
- ការពារ និងថែរក្សាផ្លូវ ដីចំណីផ្លូវ និងដីស្ថានីយអយស្ម័យយាន
- ផ្សព្វផ្សាយផលិតផល និងពង្រីកផ្ទៃដីដាំដំណាំម្រេច និងធុរេន
- ការពារដីកសិកម្ម និងអភិវឌ្ឍវិស័យកសិកម្មបែបទំនើប
- លើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ និងប្រើប្រាស់រថយន្តដើរដោយអាគុយ
- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការផ្សេងៗ ក្នុងការការពារប្រភពផ្គត់ផ្គង់ទឹកបណ្តាលមកពីការអភិវឌ្ឍក្រុង។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកែប មានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៧.១- យន្តការ

យន្តការថ្នាក់ជាតិ ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកែប ចក្ខុវិស័យឆ្នាំ២០៣០ មាន៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័ន តាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តន៍ប្លង់គោលប្រើប្រាស់ដីក្រុងកែបចក្ខុវិស័យឆ្នាំ២០៣០ មាន៖ រដ្ឋបាលខេត្តកែប គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប គណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តកែប គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប មន្ទីរ អង្គភាពរបស់ខេត្ត និងអាជ្ញាធរក្រុង សង្កាត់។

### ៧.២- ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកែបចក្ខុវិស័យឆ្នាំ២០៣០ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្ត មានជាអាទិ៍៖ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការកំណត់តំបន់ឧទ្យានជាតិកែប អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុងនិងទីប្រជុំជន សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### ៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែបមានភារកិច្ចៈ

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកែប ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើ ត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗ សម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ ឆ្នាំ កម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង និងសង្កាត់។
- ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីនេះ ក្នុងរយៈពេល៥ ឆ្នាំម្តង ស្របតាមគោលការណ៍និងនីតិវិធីដែលបានកំណត់ ឬតាមពេលវេលានិងតម្រូវការចាំបាច់ជាក់ស្តែង សំដៅបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តប្លង់គោលប្រើប្រាស់ដីនេះ ជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប រដ្ឋបាលខេត្តកែប ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដីនិងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដែលជាកត្តាគូសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដីក្រុងកែប ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយចីរភាព។

## ៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ តាមរយៈការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្លង់គោលប្រើប្រាស់ដីក្រុងកែប ត្រូវបានរៀបចំឡើងនិងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គឺជាឧបករណ៍គតិយុត្តគោល សម្រាប់ការអនុវត្តនិងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យដ៏មានសារៈសំខាន់ ដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ ២០៣០ គឺ «ក្រុងកែបជាទីក្រុងទំនើបមានខ្យល់អាកាសធម្មជាតិបរិសុទ្ធ ឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក សម្រាប់ការស្នាក់នៅ ប្រកបការងារ និងទេសចរណ៍ ដែលមានគុណភាពបរិស្ថានរស់នៅល្អ ផាសុកភាព និងសុភមង្គលល្អ តាមរយៈការអភិវឌ្ឍជាទីក្រុង ១).គោលដៅទេសចរណ៍ឆ្នេរសមុទ្រ កោះ ធម្មជាតិ ដែលស្អាតបំផុតលើសកលលោក, ២).ទីក្រុងបៃតង បុរីលំនៅឋានស្ងប់ស្ងាត់ មជ្ឈមណ្ឌលការងារ ធុរកិច្ច អប់រំ សិក្សាស្រាវជ្រាវ ដែលមានហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម និងគុណភាពបរិស្ថានរស់នៅបៃតងធម្មជាតិល្អប្រណីត

ប្រកបដោយសុភមង្គល, ៣).គ្រប់គ្រង និងអភិបាលកិច្ចល្អ, ៤).ចីរភាព តុល្យភាព និងសមាហរណកម្មការអភិវឌ្ឍ ប្រកបដោយទឹកសមុទ្រខៀវស្រងាត់ និងខ្យល់អាកាសល្អបរិសុទ្ធ, និង ៥).ជ័យលាភីទីក្រុងឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ដែលមានភ្ញៀវទេសចរជាតិ និងអន្តរជាតិមកសម្រាកលម្ហែកម្សាន្តគ្រប់រដូវកាល» និងដើម្បីរួមចំណែកអភិវឌ្ឍនិងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនផ្នែកធុរកិច្ច និងសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអនុវត្ត តាមដាន និងវាយតម្លៃចំពោះប្លង់គោលប្រើប្រាស់ដីក្រុងកែប ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត ថ្នាក់ក្រុង អាជ្ញាធរមានសមត្ថកិច្ច ត្រូវជំរុញការផ្សព្វផ្សាយនិងអនុវត្តន៍ ឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់នូវប្លង់គោលប្រើប្រាស់ដីក្រុងកែប ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ហើយត្រូវរាយការណ៍ពីលទ្ធផលនៃការអនុវត្តជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**៩-អនុសាសន៍**

ដើម្បីឱ្យប្លង់គោលប្រើប្រាស់ដីក្រុងកែបអនុវត្តមានប្រសិទ្ធភាព រដ្ឋបាលក្រុង និងរដ្ឋបាលខេត្ត ត្រូវយកចិត្តទុកដាក់៖

ទី១.អនុវត្តបទប្បញ្ញត្តិប្រើប្រាស់ដីតាមតំបន់នីមួយៗ និងត្រូវបន្តរៀបចំផែនការប្រើប្រាស់ដី ព្រមទាំងប្លង់លម្អិតនគរូបនីយកម្ម ចុះបញ្ជីដីធ្លីឱ្យបានច្បាស់លាស់ និងរៀបចំបទប្បញ្ញត្តិនានាក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីនិងសំណង់ឱ្យមានប្រសិទ្ធភាព។

ទី២.រៀបចំផែនការសកម្មភាព និងគម្រោងវិនិយោគតាមលំដាប់អាទិភាព ដើម្បីផ្សព្វផ្សាយ កៀរគរដៃគូរអភិវឌ្ឍន៍ និងអ្នកវិនិយោគ ស្របតាមច្បាប់វិនិយោគ និងបទដ្ឋានគតិយុត្តជាធរមាន។

ទី៣.លើកម្ពស់សមត្ថភាពមន្ត្រី និងបណ្តុះបណ្តាលធនធានមនុស្សថ្នាក់ក្រុង និងថ្នាក់ខេត្ត ដើម្បីធានាការគ្រប់គ្រង និងអភិបាលកិច្ចល្អ។

ទី៤.តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកែបប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងត្រូវធ្វើបច្ចុប្បន្នកម្មដោយត្រូវកត់ត្រាទុកជាប្រចាំនូវស្ថានភាពវិវត្តរបស់ក្រុង សម្រាប់ស្នើសុំកែសម្រួលសរុបក្នុងរយៈពេល៥ (ប្រាំ)ឆ្នាំម្តង និងស្នើសុំសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ស្របតាមបទដ្ឋានគតិយុត្តជាធរមាន។

ទី៥.រៀបចំកញ្ចប់ថវិកាថ្នាក់ខេត្ត និងថ្នាក់ក្រុង សម្រាប់អនុវត្តគម្រោងផែនការជួសជុល ថែទាំ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលម្អសាធារណៈ។

ទី៦.ស្នើសុំសហការ និងគាំទ្រពីគ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកែប ឱ្យមានប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្មល្អប្រសើរ។

# សន្ទានុក្រម

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈវិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំង តំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព សមធម៌ និងសមាហរណកម្ម។

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ ថ្នាក់ខេត្ត** ជាផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗ ក្នុងក្របខណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុប សម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុងព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍និងអភិរក្សទីក្រុង ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដីនិងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍ និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍន៍ទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើនទីក្រុង ដែលរួមមានការបង្ហាញអំពីការរៀបចំការរចនាទម្រង់ រូបរាង និងសោភ័ណភាពនៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន ដោយប៉ាន់ប្រមាណពីសក្តានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍនិងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លម្ហសាធារណៈ និងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍ គិតជាភាគរយ។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

**តំបន់ស្នូលនៃការអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់ សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

**អ័ក្សនៃការអភិវឌ្ឍ** សំដៅដល់បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀត ដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**ប៉ូលអភិវឌ្ឍន៍** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

**តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។

**បណ្តាញបៃតង** សំដៅដល់សួនសាធារណៈ និងដើមឈើដែលរៀបចំប្រទាក់ក្រឡាគ្នាតាមចិញ្ចើមផ្លូវភ្ជាប់ទៅសួនទីក្រុង។

**ការត្រួតពិនិត្យការអភិវឌ្ឍ** សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**ឆ្នេរសមុទ្រ** សំដៅដល់ចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល។ ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានាជាថ្មី ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម□

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០ (សាមសិប) ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ) ម៉ែត្រ ចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃ ឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

**ដីចំណីឆ្នេរសមុទ្រ** សំដៅដល់ផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រ ជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។ ប្រវែង ឬទំហំដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់ដូចខាងក្រោម□

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រត្រូវកំណត់យ៉ាងតិច៥០ (ហាសិប) ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

**តំបន់រណប** សំដៅដល់តំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រ និងផ្លូវស្របបន្ទាប់មួយទៀតដែលស្ថិតក្នុងទិសខាងដីគោក។

**ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ** សំដៅដល់ផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

**ផ្លូវសាធារណៈតាមបណ្តោយដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន** សំដៅដល់ផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានទាំងនោះ ដែលខណ្ឌចែកដីចំណីដៃ សមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន។

**ដៃសមុទ្រ** សំដៅដល់ផ្ទៃទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃដៃសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។ ទំហំដីចំណីដៃសមុទ្រត្រូវកំណត់ចម្ងាយ៣០(សាមសិប) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។

**ផ្លូវទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ** សំដៅដល់ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្ដែតបាន។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្ដែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្ដែតបាន ត្រូវកំណត់ចម្ងាយ២០ (ម្ភៃ) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់បំផុតនៅរដូវវស្សា។

**កោះ** សំដៅដល់ផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូច ធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

**ដែនទឹកសមុទ្រ** សំដៅដល់ផ្ទៃទឹកខាងលើនិងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ីនិងជីវៈចម្រុះគ្រប់ប្រភេទ។

**អាងទន្លេ** សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់ បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**សមុទ្រ** សំដៅដល់ប្រភពធនធានទឹកប្រៃ និងជាកន្លែងទទួលរំហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**ទន្លេ** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និង ពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

**ស្ទឹង** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរង ទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

**ព្រែក** សំដៅដល់ផ្លូវទឹកធម្មជាតិ ឬសិប្បនិម្មិតដែលនាំទឹកចេញឬចូលពីទន្លេ ឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះ និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

**ជ្រោះ** សំដៅដល់ជ្រលង ឬល្បាក់ទឹកធម្មជាតិដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះ ដោយសារចរន្តទឹកពីតំបន់ភ្នំ ឬតំបន់ខ្ពង់រាប។

**បឹងបួ** សំដៅដល់ល្ហាលទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**អាងទឹក** សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិ ឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។

**ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ។

**ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម** សំដៅដល់រោងចក្រកសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួចមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់ទីរមនីយដ្ឋាន ឬមជ្ឈមណ្ឌលកម្សាន្ត។

**សំណល់រាវ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

**ប្រព័ន្ធលូ** សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន៖ តំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ(បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)។

**អាងបង្គន់អនាម័យ** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។

**ឯកសារឧបសម្ព័ន្ធ**

- ផែនទីបែងចែកតំបន់ប្រើប្រាស់ដីក្រុងកែប
- ផែនទីបណ្តាញផ្លូវថ្នល់ក្រុងកែប
- ផែនទីព្រំប្រទល់រដ្ឋបាលក្រុងកែប
- ផែនទីរូបថតពីលើអាកាសក្រុងកែប៕

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនទីបែងចែកតំបន់ប្រើប្រាស់ដីក្រុងកែប




**ផែនទីតំបន់**




ប្រទេសកម្ពុជា ជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្តោយទី១០២អង្សា ដល់ ១០៨អង្សា និង រយៈទទឹងទី១០អង្សា ដល់ ១៥អង្សា ។

**ផែនទីព្រះរាជាណាចក្រកម្ពុជា**



ខេត្តកែប

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១ ០៣៥គីឡូម៉ែត្រក្រឡា ដែលក្នុងនោះ មានបណ្តោយ ៥៦០គីឡូម៉ែត្រ និងមានទទឹង ៤៤០គីឡូម៉ែត្រ ព្រមទាំង មានព្រំប្រទល់ដីគោកជាប់ប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ប្រវែង ២ ១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០គីឡូម៉ែត្រ ។

## ខេត្តកែប

ខេត្តកែបស្ថិតនៅភាគនិរតីនៃប្រទេសដែលមានចម្ងាយ ១៧៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ។ ខេត្តកែបមានព្រំប្រទល់ជាប់នឹងខេត្តកំពត និងសមុទ្រ និងមានផ្ទៃដីគោក ១៨៣.២២គីឡូម៉ែត្រក្រឡា ស្មើនឹង ១៨៣២២ហិកតា ព្រមទាំងមានស្រុកចំនួន១ គឺស្រុកដំណាក់ចង្អើរ និងក្រុងចំនួន១ គឺក្រុងកែប ក្នុងនោះមានកោះចំនួន ១៣ កោះ ។




**ក្រុងកែប**

ក្រុងកែបស្ថិតនៅភាគខាងលិចនៃខេត្តកែប និងមានចម្ងាយ១៧៥គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៣ និងផ្លូវជាតិលេខ៣៣ និងមានចម្ងាយ ២៣គីឡូម៉ែត្រពីទីរួមខេត្តកំពត តាមបណ្តោយផ្លូវជាតិ លេខ៣៣ ។
ក្រុងកែបមានផ្ទៃដីគោក ៧៥.៥២គីឡូម៉ែត្រក្រឡា ស្មើនឹង ៧ ៥៥២ហិកតា និងមានកោះចំនួន ១៣ កោះ ចែកចេញជា ០៣សង្កាត់ គឺសង្កាត់អូរក្រសារ សង្កាត់ព្រៃធំ និងសង្កាត់កែប ។




## ការពិពណ៌នា




## មាត្រដ្ឋានផែនទី

**មាត្រដ្ឋាន ១ : ២៣ ០០០**

0 0.5 1 2 3 4 គ.ម.

១ សង់ទីម៉ែត្រលើផែនទី ស្មើនឹង ២៣០ម៉ែត្រលើដីជាក់ស្តែង

គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ។

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប ដែលមានលេខាធិការដ្ឋានមួយជា
សេនាធិការ ដឹកនាំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តកែប ។
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប ដែលមានក្រុមការងារមួយជា
សេនាធិការ ដឹកនាំដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុងកែប ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប

# ផែនទីបណ្តាញផ្លូវថ្នល់ក្រុងកែប




ផែនទីតំបន់




ប្រទេសកម្ពុជា ជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្តោយទី១០២អង្សា ដល់ ១០៨អង្សា និង រយៈទទឹងទី១០អង្សា ដល់ ១៥អង្សា។

ផែនទីព្រះរាជាណាចក្រកម្ពុជា




ប្រទេសកម្ពុជាមានផ្ទៃដី ១៨១ ០៣៥គីឡូម៉ែត្រក្រឡា ដែលក្នុងនោះ មានបណ្តោយ ៥៦០គីឡូម៉ែត្រ និងមានទទឹង ៤៤០គីឡូម៉ែត្រ ព្រមទាំង មានព្រំប្រទល់ដីគោកជាប់ប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ប្រវែង ២ ១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០គីឡូម៉ែត្រ។

## ខេត្តកែប

ខេត្តកែបស្ថិតនៅភាគនិរតីនៃប្រទេសដែលមានចម្ងាយ ១៧៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ ខេត្តកែបមានព្រំប្រទល់ជាប់នឹងខេត្តកំពត និងសមុទ្រ និងមានផ្ទៃដីគោក ១៨៣.២២គីឡូម៉ែត្រក្រឡា ស្មើនឹង ១៨៣២២ហិកតា ព្រមទាំងមានស្រុកចំនួន១ គឺស្រុកដំណាក់ចង្អើរ និងក្រុងចំនួន១ គឺក្រុងកែប ក្នុងនោះមានកោះចំនួន ១៣ កោះ។




ក្រុងកែប

ក្រុងកែបស្ថិតនៅភាគខាងលិចនៃខេត្តកែប និងមានចម្ងាយ១៧៥គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៣ និងផ្លូវជាតិលេខ៣៣ និងមានចម្ងាយ ២៣គីឡូម៉ែត្រពីទីរួមខេត្តកំពត តាមបណ្តោយផ្លូវជាតិ លេខ៣៣។

ក្រុងកែបមានផ្ទៃដីគោក ៧៩.៥២គីឡូម៉ែត្រក្រឡា ស្មើនឹង ៧ ៩៥២ហិកតា និងមានកោះចំនួន ១៣ កោះ ចែកចេញជា ០៣សង្កាត់ គឺសង្កាត់អូរក្រសារ សង្កាត់ព្រៃធំ និងសង្កាត់កែប។

ជើង
ត្បូង

## មាត្រដ្ឋានផែនទី

**មាត្រដ្ឋាន ១ : ២៣ ០០០**

0 0.5 1 2 3 4 គ.ម.

១ សង់ទីម៉ែត្រលើផែនទី ស្មើនឹង ២៣០ម៉ែត្រលើដីជាក់ស្តែង

គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប ដែលមានលេខាធិការដ្ឋានមួយជា សេនាធិការ ដឹកនាំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តកែប។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប ដែលមានក្រុមការងារមួយជា សេនាធិការ ដឹកនាំដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុងកែប។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប

# ផែនទីព្រំប្រទល់រដ្ឋបាលក្រុងកែប










## ការពិពណ៌នា




## មាត្រដ្ឋានផែនទី

**មាត្រដ្ឋាន ១ : ២៣ ០០០**

0 0.5 1 2 3 4 គ.ម.

១ សង់ទីម៉ែត្រលើផែនទី ស្មើនឹង ២៣០ម៉ែត្រលើដីជាក់ស្តែង

គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ។

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប ដែលមានលេខាធិការដ្ឋានមួយជា
សេនាធិការ ដឹកនាំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តកែប ។
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប ដែលមានក្រុមការងារមួយជា
សេនាធិការ ដឹកនាំដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុងកែប ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប

# ផែនទីរូបថតពីលើអាកាសក្រុងកែប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ




## ផែនទីតំបន់




ប្រទេសកម្ពុជា ជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្តោយទី១០២អង្សា ដល់ ១០៨អង្សា និងរយៈទទឹងទី១០អង្សា ដល់ ១៥អង្សា ។

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១ ០៣៥គីឡូម៉ែត្រក្រឡា ដែលក្នុងនោះមានបណ្តោយ ៥៦០គីឡូម៉ែត្រ និងមានទទឹង ៤៤០គីឡូម៉ែត្រ ព្រមទាំងមានព្រំប្រទល់ដីគោកជាប់ប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ប្រវែង ២ ១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០គីឡូម៉ែត្រ ។

## ផែនទីព្រះរាជាណាចក្រកម្ពុជា




## ខេត្តកែប

ខេត្តកែបស្ថិតនៅភាគនីរតីនៃប្រទេសដែលមានចម្ងាយ ១៧៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ។ ខេត្តកែបមានព្រំប្រទល់ជាប់នឹងខេត្តកំពត និងសមុទ្រ និងមានផ្ទៃដីគោក ១៨៣.២២គីឡូម៉ែត្រក្រឡា ស្មើនឹង ១៨៣២២ហិកតា ព្រមទាំងមានស្រុកចំនួន១ គឺស្រុកដំណាក់ចង្អើរ និងក្រុងចំនួន១ គឺក្រុងកែប ក្នុងនោះមានកោះចំនួន ១៣ កោះ ។




### ក្រុងកែប

ក្រុងកែបស្ថិតនៅភាគខាងលិចនៃខេត្តកែប និងមានចម្ងាយ១៧៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៣ និងផ្លូវជាតិលេខ៣៣ និងមានចម្ងាយ ២៣គីឡូម៉ែត្រពីទីរួមខេត្តកំពត តាមបណ្តោយផ្លូវជាតិលេខ៣៣ ។
ក្រុងកែបមានផ្ទៃដីគោក ៧៥.៥២គីឡូម៉ែត្រក្រឡា ស្មើនឹង ៧ ៥៥២ហិកតា និងមានកោះចំនួន ១៣ កោះ ចែកចេញជា ០៣សង្កាត់ គឺសង្កាត់អូរក្រសារ សង្កាត់ព្រៃធំ និងសង្កាត់កែប ។




## ការពិពណ៌នា




## មាត្រដ្ឋានផែនទី

មាត្រដ្ឋាន ១ : ២៣ ០០០

0 0.5 1 2 3 4 គ.ម.

១ សង់ទីម៉ែត្រលើផែនទី ស្មើនឹង ២៣០ម៉ែត្រលើដីជាក់ស្តែង

គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ។

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការ ដឹកនាំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តកែប ។
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប ដែលមានក្រុមការងារមួយជាសេនាធិការ ដឹកនាំដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុងកែប ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

# ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងកែប ចក្ខុវិស័យឆ្នាំ២០៣០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ..០០១ សសរ.. ចុះថ្ងៃ........................ខែ..........................ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹង ថ្ងៃទី...០៥..........ខែ......................ឆ្នាំ២០១៨










**ការពិពណ៌នា**

**មាត្រដ្ឋានផែនទី**

មាត្រដ្ឋាន ១ : ២៣ ០០០

0 0.5 1 2 3 4 គ.ម.

១ សង់ទីម៉ែត្រលើផែនទី ស្មើនឹង ២៣០ម៉ែត្រលើដីជាក់ស្តែង

លេខ: ០០១ សសរ

បានឃើញនិងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ..................ខែ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ត្រូវនឹង ថ្ងៃទី...០៥.........ខែ..................ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

ជា សុផារ៉ា

លេខ:..................

បានឃើញនិងពិនិត្យត្រឹមត្រូវ

គោរពជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ..................ខែ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ត្រូវនឹង ថ្ងៃទី...០៥.........ខែ..................ឆ្នាំ២០១៨

**អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

បណ្ឌិត ប៉ែន សុផល

លេខ:..................

បានឃើញនិងឯកភាព

គោរពជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។

ធ្វើនៅខេត្តកែប ថ្ងៃ..................ខែ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ត្រូវនឹង ថ្ងៃទី..................ខែ..................ឆ្នាំ២០១៨

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប**

គែន សត្ថា

លេខ:..................

បានឃើញនិងឯកភាព

គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជា

ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប មេត្តាពិនិត្យនិងសម្រេច ។

ធ្វើនៅក្រុងកែប ថ្ងៃ..................ខែ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ត្រូវនឹង ថ្ងៃទី..................ខែ..................ឆ្នាំ២០១៨

**អភិបាលនៃគណៈអភិបាលក្រុង និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប**

ខិត សុខា

គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ។

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកែប ដែលមានលេខាធិការដ្ឋានមួយជា
សេនាធិការ ដឹកនាំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តកែប ។
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប ដែលមានក្រុមការងារមួយជា
សេនាធិការ ដឹកនាំដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុងកែប ។